**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ២០៧/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ១០កើត ខែកត្តិក ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា គ.ស. ២០១៥

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពអង្គភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្ត លើផ្លូវជនបទក្រាលកៅស៊ូ និងបេតុងក្នុងខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៤២/១៤ ក.អ.ជ.ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំដែលបើកបរលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសលេខ ១៩៥/១៤ ក.អ.ជ/ប្រ.ក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

## សម្រេច

**ប្រការ ១.-** តែងតាំងសមាសភាពអង្គភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្តលើបណ្តាញផ្លូវជនបទក្រោលកោស៊ូ និងបេតុងក្នុងខេត្តត្បូងឃ្មុំ ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោក | **អាន ស៊ីណា** | ជាប្រធាន |
| ២. | លោក | **មាស សម្បត្តិ** | ជាអនុប្រធាន |
| ៣. | លោក | **ស សេន** | ជាសមាជិក |
| ៤. | លោក | **ជៀស គេង** | ជាសមាជិក |
| ៥. | លោក | **យ៉េម សាឌុង** | ជាសមាជិក |
| ៦. | លោក | **សុខ ចន្ទ្រា:** | ជាសមាជិក |

**ប្រការ ២.-** អង្គភាពត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងខុសទំហំ មានភារកិច្ចដូចខាងក្រោម÷

- អនុវត្តសកម្មភាពត្រួតពិនិត្យទម្ងន់ និងខុសទំហំនៅលើផ្លូវជនបទ ទៅតាមកាលវិភាគការងារដែលរៀបចំដោយគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ
- ធានាថាឧបករណ៍ថ្លឹងទម្ងន់មានដំណើរការត្រឹមត្រូវ ដោយមានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវដែលមានសុពលភាព
- ធានាថាឧបករណ៍វាស់ទំហំយានយន្តមានដំណើរការត្រឹមត្រូវ
- បញ្ជាយានយន្តឱ្យចូលកន្លែងថ្លឹងទម្ងន់ និងវាស់ទំហំប្រកបដោយសុវត្ថិភាព
- ថ្លឹងទម្ងន់យានយន្តដោយប្រើជញ្ជីងថ្លឹងទម្ងន់ និងវាស់ទំហំយានយន្តដោយប្រើឧបករណ៍វាស់ទំហំ
- រក្សាកំណត់អត្រាគណនេយ្យនៃការចំណាយរបស់អង្គភាពត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងខុសទំហំ
- ធ្វើការថែរក្សារាល់ឧបករណ៍ទាំងអស់តាមតម្រូវការ
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ និងតាមពេលកំណត់អំពីលទ្ធផលនៃសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំ
- អនុវត្តកិច្ចការផ្សេងៗទៀតទាក់ទងទៅនឹងសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំ តាមការស្នើឡើងដោយគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ។



h

**ប្រការ ៣.-** ប្រធានអង្គភាពត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងខុសទំហំ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព
- រៀបចំសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំដោយពិចារណាអំពីសុវត្ថិភាពរបស់បុគ្គលិកអង្គភាពត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងខុសទំហំ អ្នកប្រើប្រាស់ផ្លូវថ្នល់ និងត្រួតពិនិត្យ និងសាធារណជន នឹងរក្សាសៀវភៅកំណត់ត្រាសុខភាព និងសុវត្ថិភាពអំពីព្រឹត្តិការណ៍នានា
- ធ្វើការកំណត់កម្រិតល្បឿននៅលើកំណាត់ផ្លូវ ដែលសកម្មភាពត្រួតពិនិត្យបានធ្វើឡើងដោយមានការឯកភាពពីនគរបាលចរាចរណ៍ និងកត់ត្រានៅក្នុងសៀវភៅកំណត់ត្រានូវទីតាំង កាលបរិច្ឆេទ ពេលវេលា និងចម្ងាយជាក់ស្តែងដែលវាស់វែងពីចំណុចគោលសម្រាប់សម្គាល់នានា
- រក្សាកំណត់ត្រាផ្សេងៗពាក់ព័ន្ធនឹងបទល្មើសនៃការដឹកជញ្ជូនលើសទម្ងន់ និងខុសទំហំ ការគ្រប់គ្រង និងបច្ចេកទេស នៅក្នុងសៀវភៅកំណត់ត្រារបស់ទីតាំងត្រួតពិនិត្យ
- សម្របសម្រួលការងារប្រកបដោយប្រសិទ្ធភាពជាមួយនគរបាលចរាចរណ៍
- ធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយនគរបាលចរាចរណ៍ រួមទាំងការស្វែងរកទីតាំងថ្លឹងទម្ងន់ និងវាស់ទំហំពាក់ព័ន្ធនៅក្នុងតំបន់ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អង្គភាព ដើម្បីធ្វើការត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំ
- ត្រៀមរៀបចំសម្រាប់ការដាក់ពង្រាយកម្លាំង និងធនធានប្រកបដោយប្រសិទ្ធភាព មុនពេលចេញដំណើរទៅកាន់ទីតាំងគោលដៅ
- កំណត់ពីបុគ្គលដែលទទួលខុសត្រូវក្នុងអំឡុងពេលអនុវត្តសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំ ដើម្បីណែនាំ និងបញ្ជាអ្នកបើកបរ និងអ្នកដែលទទួលខុសត្រូវនៅក្នុងមុខងារគ្រប់គ្រងរបស់អង្គភាព
- ធ្វើការពិនិត្យប្រចាំថ្ងៃដើម្បីធានាថាឧបករណ៍បរិក្ខារទាំងអស់មានដំណើរការត្រឹមត្រូវតាមស្តង់ដារ
- រាយការណ៍អំពីឧបករណ៍បរិក្ខារដែលខូចទៅគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទភ្លាមៗ និងពេញលេញ
- អនុវត្តតាមកាលវិភាគការងារដែលកំណត់ដោយគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ
- ផ្លាស់ប្តូរទីតាំងគោលដៅត្រួតពិនិត្យតាមការជាក់ស្តែង និងរាយការណ៍អំពីទីតាំងគោលដៅដល់

គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ

- ធ្វើសំណើសុំការអនុញ្ញាតពីគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ អំពីការផ្លាស់ប្តូរម៉ោងធ្វើការដែលចាំបាច់
- សម្របសម្រួលសកម្មភាពថ្លឹងទម្ងន់ និងវាស់ទំហំជាមួយនគរបាលចរាចរណ៍ក្នុងរាជធានី ខេត្ត
- គាំទ្រមន្ត្រីនគរបាលចរាចរណ៍ទាក់ទងទៅនឹងនីតិវិធីរាយការណ៍នៅពេលមានការស្នើសុំ
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែជូនគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសកម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ និងគណៈអភិបាលរាជធានី ខេត្ត។

**ប្រការ ៤.-** សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជា សុផារ៉ា

__កន្លែងទទួល__

*- ទីស្តីការគណៈរដ្ឋមន្ត្រី*
*- ក្រសួងមហាផ្ទៃ*
*- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*- សាលាខេត្តត្បូងឃ្មុំ*
*"ដើម្បីជូនជ្រាប"*
*- ដូចប្រការ ១*
*"ដើម្បីអនុវត្ត"*
*- ឯកសារ - កាលប្បវត្តិ*